ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ១១ លេខ ១០

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC




ក
ស
វ

Work Activities

ប្រចាំខែតុលា ឆ្នាំ២០១៨



# មាតិកា


| ល.រ | បរិយាយ | លេខទំព័រ |
|---|---|---|
| I- | កិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | |
| | - ឯកឧត្តម ទេសរដ្ឋមន្ត្រី **យឹម ណុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្នុងជំនួបជាមួយវិទ្យាស្ថានវិទ្យាសាស្ត្រកសិកម្មត្រូពិចចិន | ១-២ |
| II- | សកម្មភាពការងាររបស់ក្រុមវាយតម្លៃលើផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត(ក្រុម RIA) | |
| | ១- ប្រជុំប្រចាំត្រីមាសទី៣ ឆ្នាំ២០១៨ ស្តីពីកម្មវិធីវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត | ៣-៥ |
| | ២- បើកវគ្គបណ្តុះបណ្តាល ស្តីពីការវិភាគបន្ទុកចំណាយ និងផលចំណេញ នៃលិខិតបទដ្ឋានគតិយុត្តដល់មន្ត្រីរាជការក្រសួងរ៉ែ និងថាមពល | ៦-៨ |
| III- | កិច្ចប្រជុំស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែកញ្ញា ឆ្នាំ២០១៨ | ៩-១៦ |
| IV- | សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី **យឹម ណុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែតុលា ឆ្នាំ២០១៨ | ១៧-១៩ |

# ឯកឧត្តម ទេសរដ្ឋមន្ត្រី យឹម ឈុលឡា
# ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
# ក្នុងជំនួបជាមួយវិទ្យាស្ថានវិទ្យាសាស្ត្រកសិកម្មត្រូពិចចិន

## (Chinese Academy of Tropical Agricultural Sciences-CATAS)



នៅថ្ងៃអង្គារ ៦រោច ខែអស្សុជ ឆ្នាំច ព.ស ២៥៦២ ត្រូវនឹងរសៀលថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ នៅទីស្តីការគណៈរដ្ឋមន្ត្រី ឯកឧត្តម ទេសរដ្ឋមន្ត្រី **យឹម ឈុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នៃទីស្តីការគណៈរដ្ឋមន្ត្រី បានដឹកនាំប្រជុំជំនួបពិភាក្សាជាមួយបណ្ឌិតសភាវិទ្យាសាស្ត្រកសិកម្មត្រូពិចចិន ដែលដឹកនាំដោយលោក **លីវ គ័រនៅ** (Mr. Liu  Guodao)



អនុប្រធានវិទ្យាស្ថានវិទ្យាសាស្ត្រកសិកម្មត្រូពិចចិន និងមានសហការីអមដំណើរមួយចំនួនដូចជា លោក **លីវ អិនភីង** (Mr. Liu Enping) នាយកវិទ្យាស្ថានវិទ្យាសាស្ត្រនិងព័ត៌មានវិទ្យា លោកស្រី **កៅ ស៊ីវយុន** នាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលនៃវិទ្យាស្ថានវិទ្យាសាស្ត្រកសិកម្មត្រូពិចចិន និងមន្ត្រីសំខាន់ៗ មួយចំនួនទៀត។

ភាគីទាំងពីរបានពិភាក្សារកលទ្ធភាពធ្វើកិច្ចសហប្រតិបត្តិការរវាង ECOSOCC និង CATAS ដើម្បីធ្វើការសិក្សាស្រាវជ្រាវរួមគ្នាលើបញ្ហាដែលកម្ពុជាកំពុងប្រឈមក្នុងការអភិវឌ្ឍវិស័យកសិកម្ម និងតម្រូវការបណ្តុះបណ្តាលលើជំនាញមួយចំនួនដែលចាំបាច់ ដើម្បីលើកកម្ពស់សមត្ថភាពរបស់ ECOSOCC៕



# ១- ប្រជុំប្រចាំត្រីមាសទី៣ ឆ្នាំ២០១៨ ស្តីពី កម្មវិធីវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត




កាលពីព្រឹក ថ្ងៃពុធ ៨កើត ខែអស្សុជ ឆ្នាំច ព.ស២៥៦២ ត្រូវនឹងថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៨ នៅទីស្តីការគណៈរដ្ឋមន្ត្រី ឯកឧត្តម **ឃឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និងជាប្រធានក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត (RET) តំណាង ឯកឧត្តម **ឃឹម ណុលឡា** ទេសរដ្ឋមន្ត្រី ប្រធាន ECOSOCC បានដឹកនាំប្រជុំបូកសរុបការងារអនុវត្តកម្មវិធីនៃការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (RIA) ប្រចាំត្រីមាសទី៣ ឆ្នាំ២០១៨ ដើម្បីពិនិត្យវាយតម្លៃលើការងារអនុវត្តកន្លងមក និងលើកផែនការសកម្មភាពសម្រាប់អនុវត្តក្នុងត្រីមាសទី៤ ឆ្នាំ២០១៨ និងទិសដៅបន្តទៀតក្នុងឆ្នាំ២០១៩។ សិក្ខាកាមបានចូលរួមក្នុងថ្ងៃនេះមានចំនួនប្រមាណ ១០០ រូប។

បច្ចុប្បន្ន ក្រសួង ស្ថាប័ន ដែលបានចូលរួមក្នុងកម្មវិធីRIA មានចំនួន១៩៖ ក្រុមប្រតិបត្តិលិខិតបទដ្ឋាន

គតិយុត្តរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម ក្រសួងរ៉ែនិងថាមពល ក្រសួងបរិស្ថាន ក្រសួងទេសចរណ៍ ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកសិកម្មរុក្ខាប្រម៉ាញ់និងនេសាទ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងសុខាភិបាល ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងសាធារណៈការនិងដឹកជញ្ជូន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ក្រសួងយុត្តិធម៌ ក្រសួងការពារជាតិ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ។

ការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត(RIA) គឺជាទម្លាប់អនុវត្តល្អសម្រាប់ដំណើរការរៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្ត (GRP- Good Regulatory Practices) ដែលផ្តល់ផលចំណេញច្រើន ហើយមានប្រទេសអភិវឌ្ឍជាច្រើនដែលជាសមាជិកនៃ OECD (អង្គការអភិវឌ្ឍសេដ្ឋកិច្ចនិងសហប្រតិបត្តិការ) និងប្រទេស ASEAN បានទទួលស្គាល់ និងអនុវត្តយ៉ាងទូលំទូលាយ ព្រោះគេទទួលស្គាល់ថា៖




• លិខិតបទដ្ឋានមានគុណភាពខ្ពស់ ដែលមានអភិបាលកិច្ចល្អ និង ការអភិវឌ្ឍសេដ្ឋកិច្ច;

• អ្នកធ្វើសេចក្តីសម្រេចអាចធ្វើការសម្រេចបញ្ញត្តិកម្មប្រកបទៅដោយទិន្នន័យ ផ្អែកលើការអនុវត្តជាក់ស្តែង;

• បង្កើនតម្លាភាព និងកសាងជំនឿទុកចិត្តដល់សាធារណៈជន ដោយសារមានគោលការណ៍ណែនាំច្បាស់លាស់សម្រាប់កិច្ចពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ;

• ជួយកាត់បន្ថយបន្ទុកចំណាយរបស់រាជរដ្ឋាភិបាលលើការអនុវត្ត និងបន្ទុកចំណាយប្រតិបត្តិការរបស់ធុរកិច្ច



អភិបាលកិច្ចល្អ គឺជាចំណុចកណ្តាលនៃរបៀបវារៈរបស់រាជរដ្ឋាភិបាលដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណ។ ដូច្នេះរាជរដ្ឋាភិបាលបានដាក់ឲ្យអនុវត្តនូវកម្មវិធី RIA ដែលអាចនឹងកាត់បន្ថយការិយាធិបតេយ្យ កាត់បន្ថយបន្ទុកចំណាយមិនចាំបាច់លើធុរកិច្ចដើម្បីលើកកម្ពស់ភាពប្រកួតប្រជែង និងកាត់បន្ថយភាពច្រើនហួស ឬភាពជាន់គ្នានៃលិខិតបទដ្ឋានគតិយុត្ត។ល។

# ២- បើកវគ្គបណ្តុះបណ្តាលស្តីពី ការវិភាគបន្ទុកចំណាយនិងផលចំណេញនៃលិខិតបទដ្ឋានគតិយុត្ត ដល់មន្ត្រីរាជការក្រសួងរ៉ែ និងថាមពល

## ក្រោមកម្មវិធីវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី លេខ៨៨៣៤ ចាប់ពីថ្ងៃទី១៨ ដល់ ១៩ ខែតុលា ឆ្នាំ២០១៨

## នៅអគ្គនាយកដ្ឋានប្រេងកាត ក្រសួងរ៉ែ និងថាមពល




កាលពីព្រឹក ថ្ងៃព្រហស្បតិ៍ ៩កើត ខែអស្សុជ ឆ្នាំច ព.ស២៥៦២ ត្រូវនឹងថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៨ នៅអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល ឯកឧត្តម **យឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) និងជាប្រធានក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត(RET) តំណាងឯកឧត្តម ទេសរដ្ឋមន្ត្រី **យឹម ណុលឡា** ប្រធាន ECOSOCC ជាអធិបតីក្នុងពិធីបើកវគ្គបណ្តុះបណ្តាលស្តីពីការវិភាគបន្ទុកចំណាយ និងផលចំណេញ (CBA-Cost Benefit Analysis) នៃលិខិតបទដ្ឋានគតិយុត្ត ដល់មន្ត្រីរាជការក្រសួងរ៉ែនិងថាមពល ក្រោមកម្មវិធីវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត(Regulatory Impact Assessment-RIA) ជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី លេខ៨៨៣៤។ ក្នុងឱកាសនោះក៏



មានវត្តមាន ឯកឧត្តម **ស៊ុយ ឌីម៉ង់** អគ្គនាយក ក្រសួងរ៉ែ និងថាមពល បានថ្លែងចំណាប់អារម្មណ៍បើកវគ្គបណ្តុះបណ្តាលផងដែរ។ សិក្ខាកាមបានចូលរួមក្នុងថ្ងៃនេះមានចំនួនប្រមាណ ៦០ រូប ហើយវាគ្មិនមានឯកឧត្តម **ម៉ិច សុខា** អគ្គលេខាធិការរងECOSOCC និងជាអនុប្រធានអចិន្ត្រៃយ៍ក្រុមប្រតិបត្តលិខិតបទដ្ឋានគតិយុត្ត និងឯកឧត្តម **អេង រតនមុនី** អគ្គលេខាធិការរងECOSOCC និងជាប្រធានផ្នែកបណ្តុះបណ្តាល នៃក្រុមប្រតិបត្តលិខិតបទដ្ឋានគតិយុត្ត។

អតីតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលបានចាប់ផ្តើមអនុវត្តវិធីសាស្ត្រ RIA បានសាកល្បងកាលពីឆ្នាំ២០០៨ ហើយចេញពីលទ្ធផលនេះ នៅឆ្នាំ២០១១ADBបានបន្តផ្តល់មូលនិធិគាំទ្រដើម្បីពង្រីកវិសាលភាពនៃការអនុវត្ត RIA ដោយមុនដំបូងមានក្រសួងចំនួន៤ (MIME, MOC, MOE, MOT) ចូលរួមអនុវត្តគម្រោងសាកល្បង ដែលECOSOCC ជាដើរតួនាទីជាភ្នាក់ងារប្រតិបត្តគម្រោង ឬជាស្ថាប័នបណ្តុះបណ្តាល។

ការអនុវត្តRIAនៅកម្ពុជាទទួលបានលទ្ធផលល្អ ដែលនាំឲ្យADB នៅតែបន្តផ្តល់ជាជំនួយឥតសំណងហើយរាជរដ្ឋាភិបាល បានចេញសេចក្តីសម្រេចលេខ១៣២ សសរ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការបង្កើតក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ដូច្នេះក្រសួងស្ថាប័នបានចូលរួមកាន់តែច្រើន ដែលមកដល់បច្ចុប្បន្ននេះមានក្រសួងចំនួន ១៦ ព្រមទាំងស្ថាប័នចំនួន ២៖ ក្រសួងរ៉ែនិងថាមពល ក្រសួងពាណិជ្ជកម្ម ក្រសួងទេសចរណ៍ ក្រសួងបរិស្ថាន ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងអប់រំយុវជននិងកីឡា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ក្រសួងសុខាភិបាល ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងការពារជាតិ ក្រសួងយុត្តិធម៌ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ។ ប្រទេសជឿនលឿនជាច្រើនបានអនុវត្ត RIA តាំងពីយូរយារមកហើយ ក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្ត



ដែលបានផ្ដល់នូវផលចំណេញជាច្រើនដល់ប្រទេសគេ ដូចជាធ្វើឲ្យលិខិតបទដ្ឋានគតិយុត្តមានគុណភាពខ្ពស់ ដែលនាំឲ្យអភិបាលកិច្ចល្អ ជំរុញកំណើនសេដ្ឋកិច្ច បង្កើនតម្លាភាពនិងគណនេយ្យភាព កាត់បន្ថយការិយាធិបតេយ្យ កាត់បន្ថយវិសាលភាពភាពជាន់គ្នា កាត់បន្ថយបន្ទុកចំណាយរដ្ឋបាលលើការអនុវត្ត និងកាត់បន្ថយបន្ទុកចំណាយប្រតិបត្តិការរបស់ធុរកិច្ចជាដើម ហើយពិសេសទៅទៀត គឺពង្រឹងជំនឿទុកចិត្តពីសាធារណជន និងធុរជនលើលិខិបទដ្ឋានគតិយុត្ត។

ចាប់ពីឆ្នាំ២០១៥មក ប្រទេសអាស៊ានជាមួយអង្គការសហប្រតិបត្តិការអភិវឌ្ឍសេដ្ឋកិច្ចតែងតែរៀបចំកិច្ចប្រជុំស្ដីពី “បណ្ដាញប្រតិបត្តិល្អក្នុងនីតិវិធីតាក់តែងលិខិតបទដ្ឋានគតិយុត្ត( ASEAN-OECD Good Regulatory Practice Network Meeting-GRPN)” ដែលប្រទេសម៉ាឡេស៊ី និងញ៉ូសីឡែន ជាសហប្រធាន។ ប្រទេសអាស៊ានបានទទួលស្គាល់ថា RIA ជាឧបករណ៍បច្ចេកទេសល្អក្នុងការអនុវត្ត GRP-Good Regulatory Practices ដើម្បីបង្កើនប្រសិទ្ធភាពលិខិតបទដ្ឋានគតិយុត្ត សំដៅសម្រេចបាននូវកំណែទម្រង់បញ្ញត្តិកម្ម(Regulatory Reform) និងបញ្ញត្តិកម្មងាយស្រួលនៅក្នុងគោលនយោបាយបញ្ញត្តិកម្ម។ ហើយជាពិសេស CBA ជាឧបករណ៍សេដ្ឋកិច្ចមិនអាចខ្វះបាននៅក្នុងដំណើរការរបស់ RIA។ ម្យ៉ាងវិញទៀត របាយការណ៍ RIA ដែលល្អប្រសើរគឺផ្សំឡើងដោយការវិភាគ CBA បានគ្រប់ជ្រុងជ្រោយ៕

# III- កិច្ចប្រជុំស្ដីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែកញ្ញា ឆ្នាំ២០១៨




របាយការណ៍ស្ដីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ **ប្រចាំខែកញ្ញា ឆ្នាំ២០១៨** នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ ក្រោមអធិបតីភាព ឯកឧត្ដម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពី អនុប្រធាន សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង នៃ ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្ដូរប្រាក់

➡ នាខែកញ្ញា ឆ្នាំ២០១៨សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង០,៣% ធៀបនឹងខែមុន និងកើនឡើង២,៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| *ក្រុមទំនិញ:* | | *មុខទំនិញ:* | |
|---|---|---|---|
| ភោជនីយដ្ឋាន: | +៦,០% | ប្រេងសាំង: | +៨,១% |
| ការដឹកជញ្ជូន: | +៣,៧% | ឧស្ម័ន: | +៧,៣% |
| សំលៀកបំពាក់ និងស្បែកជើង: | +២,៧% | ប្រេងម៉ាស៊ូត: | +៦,៧% |
| ម្ហូបអាហារ: | +២,៥% | សាច់ជ្រូក: | +៣,៤% |
| ទំនិញ និងសេវាកម្មផ្សេងៗ | +១,៧% | ត្រីស្រស់: | +៣,២% |
| សុខាភិបាល: | +១,៥% | សាច់គោ: | +២,១% |
| ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈផ្សេង | +១,៤% | សាច់មាន់: | +២,០% |
| ទៀតគ្រឿងសង្ហារឹមនិងសម្ភារៈប្រើប្រាស់: | +០,១% | | |

តារាង១.២. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១៦–២០១៨

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា P | វិច្ឆិកា P | ធ្នូ P | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៨ | ដូចគ្នាឆ្នាំមុន | ២,០% | ២,៣% | ២,៣% | ២,៤% | ២,៩% | ២,៩% | ២,៣% | ២,៦% | ២,៦% | ២,៦% | ២,៧% | ២,៥% | ២,៥% |
| | មុន | ០,១% | ០,៤% | ០,០៤% | ០,៥% | ០,៣% | ០,១% | -០,៣% | ០,៧% | ០,៣% | -០,១% | ០,២% | ០,២% | |
| ២០១៧ | ដូចគ្នាឆ្នាំមុន | ៤,៤% | ៤,០% | ៤,២% | ៣,២% | ២,៥% | ២,៣% | ២,៣% | ២,៦% | ២,៧% | ២,១% | ២,៣% | ២,២% | ២,៩% |
| | មុន | ០,៣% | ០,១% | ០,០% | ០,៤% | -០,២% | ០,១% | ០,៣% | ០,៤% | ០,៣% | -០,២% | ០,២% | ០,៤% | |
| ២០១៦ | ដូចគ្នាឆ្នាំមុន | ៣% | ២,៣% | ២,០% | ២,៨% | ៣,១% | ៣,៣% | ៣,០% | ២,៩% | ៣,០% | ៣,៤% | ៣,៦% | ៣,៩% | ៣% |
| | មុន | -០,២% | ០,៤% | -០,២% | ១,៤% | ០,៥% | ០,២% | ០,៣% | ០,២% | ០,៣% | ០,៤% | ០ | ០,៤% | |

P: តួលេខខែតុលា វិច្ឆិកា និងធ្នូឆ្នាំ២០១៨ ជាតួលេខព្យាករ (តាមវិធីសាស្ត្រ DECOMPOSITION)

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្ដប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។
* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

ក្រាហ្វ ១.១. ចលនានិងបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់







១.៣. អត្រាប្តូរប្រាក់

| *ប្រភេទ* | *កញ្ញា*២០១៨ | *សីហា* ២០១៨ | *កញ្ញា* ២០១៧ | *ប្រភេទ* | *កញ្ញា*២០១៨ | *សីហា* ២០១៨ | *កញ្ញា* ២០១៧ |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៤០៨២៛/១$ | ៤០៨៤៛/១$ | ៤០៥៣៛/១$ | **បាត/ដុល្លារ** | ៣២,៤៣បាត/១$ | ៣២,៧៨បាត/១$ | ៣៣,៣៨បាត/១$ |
| **៛/បាត** | ១២៦៛/១បាត | ១២៥៛/១បាត | ១២១៛/១បាត | **ដុង/ដុល្លារ** | ២៣៣១០ដុង/១$ | ២៣២៨៤ដុង/១$ | ២២៦៩៧ដុង/១$ |
| **៛/ដុង** | ០,១៧៥៛/១ដុង | ០,១៧៥៛/១ដុង | ០,១៧៩៛/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់ធនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងខែកញ្ញា ឆ្នាំ២០១៨ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម:

**២.១. ចំណូលថវិកាជាតិ** : អនុវត្តបាន១៥២៥,៩ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៣៨១,៥ លានដុល្លារ ( *មធ្យមប្រចាំខែ ១០៦,៧% នៃផែនការ*) ក្នុងនោះចំណូលចរន្តចំនួន១៤៧០,៨ប៊ីលានរៀល គិតជាដុល្លារអាមេរិក ស្មើ ៣៦៧,៧ លានដុល្លារ ( *មធ្យមប្រចាំខែ ១០៧% នៃផែនការ*) និងចំណូលមូលធនចំនួន៥៥,២ប៊ីលានរៀល (តាមតួលេខ ធនាគារជាតិ)។

➢បើធៀបនឹងខែមុន ចំណូលថវិកាជាតិថយចុះ១០% ប៉ុន្តែកើនឡើង៣០,៩%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១៦-២០១៨ (ប៊ីលានរៀល)




➢នៅក្នុងចំណូលចរន្ត:

✓ចំណូលសារពើពន្ធមានចំនួន ១២៩០,៣ប៊ីលានរៀលថយចុះ១៣,៩% ធៀបនឹងខែមុនប៉ុន្តែ កើនឡើង២៧,៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន(តាមតួលេខ ធនាគារជាតិ)។

✓ចំណូលមិនមែនសារពើពន្ធ មានចំនួន១៨០,៥ប៊ីលានរៀលកើនឡើង៣,៤% ធៀបនឹងខែមុន និងកើនឡើង១៧,៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន(តាមតួលេខ ធនាគារជាតិ)។

| តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ | | | |
|---|---|---|---|
| **ចំណូលសារពើពន្ធ**<br>(ក្នុងរង្វង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | **ចំណូលមិនមែនសារពើពន្ធ**<br>(តាមតួលេខ រតនាគារជាតិ)<br>(ក្នុងរង្វង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
| ➢ ពន្ធ និងអាករគយ: :-៨,៣%<br>(អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | (+២៥,១%) | ➢អាជ្ញាបណ្ណក្នុងស្រុក : -៨៥,២% | (+១៥១,៦%) |
| | | ➢ នេសាទ:-៧៥,២% | (-៥,៣%) |
| ➢ ចំណូលពន្ធដារ: -១,៤%<br>(អគ្គនាយកដ្ឋានពន្ធដារ) | (+១៥,៦%) | ➢សម្បទានរ៉ែ: -៩០,២% | (-៦៧,៦%) |
| | | ➢ អាកាសចរណ៍ស៊ីវិល: -៥៨,៥% | (+២៤០,៣%) |

**២.២. ចំណាយថវិកាជាតិ** :អនុវត្តបាន ១៥២៨,៧ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៣៨២,២ លានដុល្លារ (*មធ្យមប្រចាំខែ ៨៣% នៃផែនការ*) ក្នុងនោះ ចំណាយចរន្តចំនួន ១២០៣,២ប៊ីលានរៀល (*មធ្យមប្រចាំខែ ៨៦% នៃផែនការ*) និងចំណាយមូលធនមានចំនួន៣២៥,៦ប៊ីលានរៀល(តាមតួលេខ រតនាគារជាតិ)។

➢ចំណាយថវិកាជាតិថយចុះ៥% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៣៥,៤%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្តថយចុះ២,៨% ធៀបនឹងខែមុនប៉ុន្តែកើនឡើង៤៣,៧%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាខែនេះមានឱនភាពចំនួន ២,៨ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ០,៧លានដុល្លារ (តួលេខរតនាគារជាតិ)។

ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១៦–២០១៨
(ប៊ីលានរៀល)




## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែកញ្ញា ឆ្នាំ២០១៨មានលក្ខណៈដូចខាងក្រោម:

➢រូបិយវត្ថុ$M_2$ មានចំនួន៨៤៦១១ប៊ីលានរៀល កើនឡើង៣,១% ធៀបនឹងខែមុន និងកើនឡើង២១,៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ **ការកើនឡើង $M_2$** ក្នុងខែនេះ ជារួមបណ្តាលមកពីការកើនឡើងនៃរូបិយវត្ថុក្រៅធនាគារ ២,៧% ប្រាក់បញ្ញើមានកាលកំណត់ និងសន្សំ ១៤,៨% និងប្រាក់បញ្ញើជារូបិយបណ្ណ២,៧%។

ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុខែកញ្ញា ឆ្នាំ២០១៨




➢ក្នុងខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារមានចំនួន១៥,៨% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន ៨៤,២% នៃរូបិយវត្ថុ$M_2$។

តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ ឆ្នាំ២០១៨

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | ១៦,៨% | ១៦,៧% | ១៥,៥% | ១៥,៣% | ១៥,៣% | ១៥,៤% | ១៦% | ១៥,៥% | ១៥,៨% | | | |
| ប្រាក់រៀលក្រៅធនាគារ | ១១,៦% | ១១,៥% | ១១,៣% | ១១,៤% | ១១,៩% | ១០,៨% | ១១,៣% | ១០,៩% | ១០,៩% | | | |

ក្រាហ្វ៣.២.បម្រែបម្រួលសមាសធាតុរូបិយវត្ថុខែសីហា ២០១៨: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន




➢**ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ** មានចំនួន៩២៧១លានដុល្លារ កើនឡើង២,២៨%ធៀបនឹងខែមុន និងកើនឡើង១០,៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ក្នុងខែនេះមានចំនួន ២៩៧៧៤ ប៊ីលានរៀលកើនឡើង៣,៨%ធៀបនឹងខែមុន និងកើនឡើង២០,១%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៣.២.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| *ផ្តល់ដោយ* | *កញ្ញា២០១៨* | *សីហា២០១៨* | *កញ្ញា២០១៧* |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ប៊ីលានរៀល) | ៧៩៦៦១ | ៧៧៧៤១ | ៦៤៩៦១ |
| ក្នុងនោះ ជារៀល | | ២៧១៧ | ១១៥៧ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ប៊ីលានរៀល) | ២០៦២១ | ២០២៧៨ | ១៦១៦៣ |
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,១១% | ៦,០៧% | ៥,៩៦% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៤៤% | ៤,៤៥% | ៤,៤២% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១១,៣៣% | ១១,២៨% | ១៤,៤៩% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១១,០៨% | ១០,៤៨% | ១១,៧៩% |
| កម្ចីជារៀលនៅហត្ថកសិករ | ១៧,៨% | ១៨,០% | ១៨% |
| កម្ចីជារៀលនៅអម្រឹត | ១៧,៩% | ១៨,០% | ១៨% |
| កម្ចីជារៀលនៅប្រាសាក់ | ១៥,៨% | ១៧,៥% | ១៧,៨% |

### ៤)ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងទេសចរណ៍

➡ក្នុងខែកញ្ញា ឆ្នាំ២០១៨ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម:

➢**កសិកម្ម**:

✓នេសាទសម្រេចបាន៩២,៣៥ពាន់តោន កើនឡើង១៦%ធៀបនឹងខែមុន និងកើនឡើង៨,៨%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢រ៉ែ និងថាមពល:

✓អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន៨៤០GWHមានការកើនឡើង៤,០%ធៀបនឹងខែមុន និងកើនឡើង២៥,០%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន៦៩៩,៣GWHមានការកើនឡើង៨,៨% ធៀបនឹងខែមុន និងកើនឡើង៨៦%ធៀបនឹងខែដូចគ្នាឆ្នាំមុន អគ្គីសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន៨៥,២GWHមានការថយចុះ២៣,០% ធៀបនឹងខែមុន និងមានការ ថយចុះ៦៤,០% ធៀបនឹងខែដូចគ្នាឆ្នាំមុន អគ្គិសនីដែលនាំចូលពីប្រទេសជិតខាងដោយ EDC មានចំនួន៤៧,៥GWHមានការ កើនឡើង១,៥%ធៀបនឹងខែមុន ប៉ុន្តែមានការថយចុះ៦,២% ធៀបនឹងខែដូចគ្នាឆ្នាំមុន និងអគ្គិសនីផ្គត់ផ្គង់ដោយប្រភពផ្សេងទៀតមានចំនួន៧,៩GWHមានការកើនឡើង៧,៣% ធៀបនឹងខែមុន និងមានការកើនឡើង២១,៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ឧស្សាហកម្ម:

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ៩៧៥,២លានដុល្លា កើនឡើង១៨%ធៀបនឹងខែមុននិង កើនឡើង៥០,៧%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៤.១. ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| ប្រភេទ | ចំនួន –កញ្ញា២០១៨ | ចំនួន–សីហា២០១៨ | ចំនួន–កញ្ញា២០១៧ |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ១៣ | ២៦ | ៣៩ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១៦១១ | ១៦៣៨ | ១៦៩២ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ៩ | ៧ | ២០ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ៦ | ១១ | ៤២ |

➢សំណង់ (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន១៨០៣,៥ពាន់ម² មានការថយចុះ២% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង១៨៤%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង៩១៥,៣លានដុល្លារមានការកើនឡើង៩%ធៀបនឹងខែមុន និងកើនឡើង៩៣៤%បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន:

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| ប្រភេទ | ពាន់ម² – កញ្ញា២០១៨ | ពាន់ម² –សីហា២០១៨ | ពាន់ម² –កញ្ញា២០១៧ |
|---|---|---|---|
| ▪ លំនៅឋាន | ៧៦២,៨ | ៤៦៧,៧ | ១១១,១ |
| ▪ ឧស្សាហកម្ម | ៤៤,៩ | ២៦៨,៤ | ៤៤,៧ |
| ▪ពាណិជ្ជកម្ម | ៩៦៨,២ | ១០១៨,៧ | ១១៨,៣ |
| ▪ ទេសចរណ៍ | ២៣,២ | ៥៤,១ | ៩,២ |
| ▪ផ្សេងៗ | ៤,៥ | ០,៣ | ០,៩ |
| អនុញ្ញាតសរុប | ១៨០៣,៥ | ១៨៣៤,៤ | ២៨៤,៣ |

✓ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាខែនេះគឺ ពាណិជ្ជកម្ម ៥៣,៦% និងលំនៅឋាន ៤២,៣% នៃផ្ទៃក្រឡាសរុប។

## ➢ការងារ

តារាង៤.៣. ការស្វែងរកការងារនិងទទួលបានការងារ

| ប្រភេទ | នាក់– កញ្ញា ២០១៨ | នាក់–សីហា ២០១៨ | នាក់–កញ្ញា ២០១៧ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ (ទីភ្នាក់ងារជាតិមុខរបរនិងការងារ) | ១៤០៥ | ១៣៤៨ | ៩១០ |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ១៧២៨១ | ១៧៧៣៤ | ១៦៦៥៧ |
| អ្នកទទួលបានការងារក្នុងប្រទេស | ១០៤១៣ | ១០២៤១ | ១២២៦៤ |
| អ្នកទទួលបានការងារក្រៅប្រទេស | ៦៨៦៨ | ៧៤៩៣ | ៤៣៩៣ |

## ➢វិនិយោគ

តារាង៤.៤.គម្រោងវិនិយោគអនុញ្ញាតដោយ ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | កញ្ញា២០១៨ | សីហា២០១៨ | កញ្ញា២០១៧ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ៤៣១,២ | ៧៥៧,៩ | ៦៤,១ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ០,០ | ៣២,០ | ០,០ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ៤៣១,២ (៤៩,៩) | ១០៧,២ (៥៨,០) | ៦៤,១ (១០,៥) |
| វិស័យទេសចរណ៍ | ០,០ | ៦៨,៣ | ០,០ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ០,០ | ៥៥០,៤ | ០,០ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ២៩ | ២០ | ១៧ |
| បង្កើតការងារ (ពាន់នាក់) | ៣៥,៩ | ៣៧,០ | ១៣,១ |

## ➢សេវាកម្ម

តារាង៤.៥.ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| ប្រភេទ | ចំនួន –កញ្ញា២០១៨ | ចំនួន–សីហា២០១៨ | ចំនួន–កញ្ញា២០១៧ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ១២៦០ | ១១៥៩ | ៤៩១ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ២៣ | ១៣ | ៦ |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ៦៣៨ | ៧៦៧ | ៤០៥ |

➢**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប៥កំពង់ផែ) មានចំនួន៨០១,៤ពាន់តោនកើនឡើង៩,៨%ធៀបនឹងខែមុន ប៉ុន្តែ ថយចុះ៥,៣% ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ:

តារាង៤.៦.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)

| | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ:+២,៨% | (+១៧,៤%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង:+០,៩% | (-៥៥,៩%) |
| ▪ កំពង់ផែកំពង់សោម:+៧,៧% | (-១០,២%) | ▪ កំពង់ផែឧកញ៉ាម៉ុង: +១៣៩,៨% | (-២៥,៣%) |

## ➢ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ចំនួន | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ១៧,២ | -១៨,២% | +១៩,៤% |
| ក្នុងនោះទទួល | ២,៦ | -១,៨% | +៣១,៨% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ៧៤,៥ | -៣០,៦% | +៧,០% |

| | | | |
|---|---|---|---|
| ក្នុងនោះទទួល | ៤៤,៨ | --២៩,២% | +៧,៨% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ១៧៧៥,៣ | -៥,៩% | -៩,៣% |
| ក្នុងនោះហៅចូល | ៥៤៩,៧ | -៥,៧% | -៧,៣% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ៥៦៩៣,៨ | -២៤,៨% | -២៧,៧% |
| ក្នុងនោះហៅចូល | ៥៦១៥,៧ | -២៥,០% | -២៨,២% |

➢ **ការធ្វើដំណើរតាមផ្លូវអាកាសនិងទេសចរណ៍**

តារាង៤.៧.អ្នកដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

| *ប្រភេទ* | *ចំនួន(ពាន់នាក់)* | *%∆ ធៀបនឹងខែមុន* | *%∆ធៀបនឹងខែដូចគ្នាឆ្នាំមុន* |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១០,៦ | -២៧,៥% | +០,៥% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ៤១,៧ | -២២,២% | +៦,១% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៦៩៣,៨ | -១២,២% | +២៣,៨% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ១៧៣,១ | -៤,៦% | +៤,១% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ៤២៦,៣ | -១៣,៧% | +១៣,៣% |
| ✓ តាមផ្លូវអាកាស | ២៩៧,១ | -១៤,៩% | +២៧,៨% |
| ✓ តាមផ្លូវគោក និងទឹក | ១២៩,២ | -១០,៩% | -១០,២% |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនាខែកញ្ញា ឆ្នាំ២០១៨ មានចំនួន ៥៥១៩,៩ប៊ីលានរៀល (ស្មើនឹង១៣៨០លានដុល្លារ ស.រ.អា.) ថយចុះ៦,២% ធៀបនឹងខែមុននិង កើនឡើង២២,០% ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %∆ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %∆□ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | -២,៩% | +១១,០% | រថយន្តសរុប (ប៊ី.ល.រ) | -១១,៧% | +២៥,៥% |
| ប្រេងម៉ាស៊ូត | +២,៥% | +១២,១% | រថយន្តសរុប (គ្រឿង) | -១២,៥% | +៩,៥% |
| ឧស្ម័ន | +១២,៦% | +២១,២% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | -១៦,១% | -១៥,៨% |
| អគ្គិសនីនាំចូលដោយ | +១,៥% | -៦,២% | ម៉ូតូ (គ្រឿង) | -១៦,៨% | +៣,៧% |
| ដែកសំណង់ | -២០,៩% | +១៣,១% | អង្ករ | -៣០,៦% | +០,២% |
| ស៊ីម៉ង់ត៍ | -៨,៧% | +០,៧% | ផ្លែឈើនិងបន្លែ | -៥,១% | -៧,១% |
| គ្រឿងអេឡិចត្រូនិក | កើនគំហុក | កើនគំហុក | ជីនិងថ្នាំកសិកម្ម | +១២,២% | +៧,២% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិ | +១៨,២% | +៧៦,៤% |

➡ **ការនាំចេញ** ខែកញ្ញា ឆ្នាំ២០១៨ មានចំនួន**៥០០៥,២**ប៊ីលានរៀល ស្មើនឹង**១២៥១,៣**លានដុល្លារ ស.រ.អា. (**៩១**% នៃការនាំចូល)ថយចុះ១០,០% ធៀបនឹងខែមុន និងកើនឡើង១២,៦%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | +៤៧,១% | -៨៦,១% | ផលិតផលនេសាទ | +១៧៨,៥% | +៤០,២% |
| វាយនភណ្ឌនិងស្បែកជើង | -៦,១% | +២៨,៨% | កៅស៊ូ | -៩,៥% | +១៨,៩% |
| អង្ករ | -៤,៩% | -៨,៥% | | | |

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែកញ្ញា ឆ្នាំ២០១៨នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចក្នុងតារាងខាងក្រោម។

តារាង៦.១. បម្រែមប្រួលគួរឲ្យចាប់អារម្មណ៍ នៃសូចនាករមួយចំនួន

| ល.រ | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ថ្លៃប្រេងសាំង | +១,៩% | +៨,១% | |
| ២ | ថ្លៃឧស្ម័ន | +២,២% | +៧,៣% | |
| ៣ | ថ្លៃប្រេងម៉ាស៊ូត | +១,២% | +៦,៧% | |
| ៤ | អនុញ្ញាតិសំណង់លំនៅឋាន | +៦៣% | +៥៨៦% | |

## ៧) សេចក្តីសន្និដ្ឋាន

១) អត្រាអតិផរណាឆ្នាំ ២០១៨ នេះ រំពឹងថាមានកម្រិតទាប ប្រហែលជាជុំវិញ ២,៥% ដែលក្នុងនោះ ក្រុមម្ហូបអាហារពុំមានការឡើងថ្លៃខ្លាំងក្លាគួរឲ្យកត់សម្គាល់ទេ ប៉ុន្តែក្រុមឥន្ធនៈមានការឡើងថ្លៃខ្លាំង បើសរុបរយៈពេល៩ខែ ឆ្នាំ២០១៨នេះ ប្រេងសាំងឡើងថ្លៃ ៨,០% ប្រេងម៉ាស៊ូតឡើងថ្លៃ ៦,៥% និងឧស្ម័នឡើងថ្លៃ ៧,៣% បើធៀបនឹង ៩ខែដូចគ្នា ឆ្នាំ២០១៧។ រហូតទៅដល់ចុងឆ្នាំរំពឹងថាថ្លៃឥន្ធនៈអាចនឹងមានការថយចុះទៅតាមនិន្នាការថ្លៃប្រេងឆៅលើទីផ្សារសកលលោក។

២) ដោយសារតម្រូវការលើសេវាសុខាភិបាលក្នុងប្រទេសចេះតែកើនឡើង ទាំងបរិមាណនិងគុណភាព និងដើម្បីកាត់បន្ថយលំហូរចំណាយរបស់ប្រជាពលរដ្ឋទៅក្រៅប្រទេសលើការពិនិត្យព្យាបាលសុខភាព ជាមួយនឹងការលើកកម្ពស់កិត្យានុភាពវិស័យសុខាភិបាលជាតិ កម្ពុជាត្រូវការវិនិយោគខ្នាតធំបន្ថែមក្នុងវិស័យនេះ ទាំងលើរចនាសម្ព័ន្ធរូបវន្ត ទាំងធនធានមនុស្ស ពិសេស ការបង្កើតមជ្ឈមណ្ឌលសុខាភិបាលខ្នាតធំជាមួយនឹងស្តង់ដារខ្ពស់ ។ ការណ៍នេះតម្រូវឲ្យមានការទាក់ទាញវិនិយោគបរទេស ដែលអាចនឹងនាំមកនូវទំនើបកម្មវិស័យសុខាភិបាល បរិក្ខា និងបច្ចេកវិទ្យទំនើប ការផលិតនិងប្រើឱសថមានគុណភាព និងចំណេះដឹង។

៣) ការហក់ឡើងកាន់តែខ្ពស់នៃវិស័យអចលនទ្រព្យ នាពេលបច្ចុប្បន្ន អាចនិងប៉ះពាល់ ដល់ការវិនិយោគសកម្មភាពសេដ្ឋកិច្ច និងថ្លៃទំនិញនៅកម្ពុជា។ កំណើនថ្លៃអចលនទ្រព្យខ្ពស់ពេក ធៀបនឹងកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ អាចនឹងធ្វើឲ្យថ្លៃឈ្នួលដីកើនឡើងយ៉ាងខ្លាំងដែរ ដែលនឹងជះឥទ្ធិពលបន្តលើថ្លៃទំនិញ និងសេវា៕

## IV- សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី យឹម ណុលឡា ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែតុលា ឆ្នាំ២០១៨

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៤/១០/១៨ ម៉ោង១៨:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងឱកាសប្រារព្ធពិធីថ្ងៃបុណ្យរួបរួមជាតិសាធារណរដ្ឋសហព័ន្ធ នៃប្រទេសអាឡឺម៉ង់ នៅសណ្ឋាគារឡឺរ៉ូយ៉ាល់។ |
| ២ | ០៥/១០/១៨ ម៉ោង០៧:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីអបអរសាទរទិវាគ្រូបង្រៀន ០៥តុលា ក្រោមប្រធានបទ "គុណភាពគ្រូជាគុណភាពមូលធនមនុស្ស សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅវិទ្យាស្ថានជាតិអប់រំ។ |
| ៣ | ១៥/១០/១៨ ម៉ោង០៧:២៤នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីគោរពព្រះវិញ្ញាណក្ខ័ន្ធ ព្រះករុណាព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ" គម្រប់ខួប៦ឆ្នាំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅព្រះបរមរូប នាមណ្ឌលសួនច្បារខាងកើត វិមានឯករាជ្យ។ |
| ៤ | ១៧/១០/១៨ ម៉ោង១៥:៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **យឹម ណុលសន** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ១៨/១០/១៨ ម៉ោង០៨:៣០នាទី | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ប្រចាំខែសីហា ឆ្នាំ២០១៨ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ២២/១០/១៨ ម៉ោង០៩:៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **ឆយ អូន** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៧ | ២៤/១០/១៨ ម៉ោង០៩:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើៈ<br>១-សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩។<br>២-សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧។<br>៣-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយជាមួយ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៨ | **២៥/១០/១៨ ម៉ោង០៩:៣០នាទី** | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយសម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩។<br>២-សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧។<br>៣-បញ្ហាផ្សេងៗ។<br>នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៩ | **២៦/១០/១៨ ម៉ោង០៨:៣០នាទី** | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩។<br>២-សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧។<br>៣-បញ្ហាផ្សេងៗ:<br>សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រីដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិលើ៖<br>៣.១-កិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល រវាងកម្ពុជា-វៀតណាម និងកម្ពុជា-ឥណ្ឌូនេស៊ី។<br>៣.២-សន្ធិសញ្ញារវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី ស្តីពីបត្យាប័ន។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១០ | **៣០/១០/១៨ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបញ្ចុះបឋមសិលាសាងសង់អគារថ្មីរបស់មន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិនព្រះកុសមៈ ក្រោមអធិបតីភាព ឯកឧត្តម **ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅមន្ទីរពេទ្យព្រះកុសមៈ។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១១ | ៣០/១០/១៨<br>**ម៉ោង១៥:៣០នាទី** | ប្រជុំពិភាក្សាការងារជាមួយគណៈប្រតិភូ នៃសាធារណៈរដ្ឋប្រជាមានិតចិន នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១២ | ៣១/១០/១៨<br>**ម៉ោង០៦:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយបងប្អូនកម្មករនិយោជិត នៅស្រុកមុខកំពូល ខេត្តកណ្តាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅភូមិកណ្តាល ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល។ |

# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in